

# កម្មវិធី Rhode Island Medicaid៖

## ការធានារ៉ាប់រងសុខភាពសម្រាប់អ្នក និងក្រុមគ្រួសាររបស់អ្នក។

Medicaid ជួយអ្នកឱ្យទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យរាល់ពេលដែលអ្នកត្រូវការ។ អ្នកអាចចុះឈ្មោះបានគ្រប់ពេល — ប៉ុន្តែកុំរង់ចាំអី! ត្រូវប្រាកដថាអ្នក និងក្រុមគ្រួសាររបស់អ្នកមានសុខភាពល្អពេញមួយឆ្នាំ។

### តើអ្នកណាខ្លះអាចមានសិទ្ធិចូលរួមបាន?

- កុមារ និងក្មេងជំទង់ដែលមានអាយុរហូតដល់ 19 ឆ្នាំ។ (កុមារទាំងអស់មានសិទ្ធិស្របតាម Cover All Kids ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ រួមទាំងកុមារដែលមិនមានឯកសារ និងអ្នកទទួលចំណាត់ការពន្យារពេលសម្រាប់ការមកដល់របស់កុមារ (DACA)។)
- ក្រុមគ្រួសារដែលមានកូន
- ស្ត្រីមានផ្ទៃពោះ
- មនុស្សចាស់
- មនុស្សដែលមានពិការភាព
- យុវជនដែល "គ្រប់អាយុចាកចេញ" ពីកម្មវិធីថែទាំកុមារក្រោមការគ្រប់គ្រងរបស់រដ្ឋ
- ពលរដ្ឋសហរដ្ឋអាមេរិក និង ជនអន្តោប្រវេសន៍ដែលកំពុងរស់នៅដោយស្របច្បាប់មួយចំនួន

**សិទ្ធិចូលរួមអាចអាស្រ័យ**ទៅលើចំណូល សមាជិកក្រុមក្នុងគ្រួសារ ឬស្ថានភាពពិការភាពរបស់អ្នក។ ទោះបីជាអ្នកមិនមានសិទ្ធិចូលរួមពីមុនក៏ដោយ ឥឡូវនេះ អ្នកអាចមានសិទ្ធិចូលរួមបានហើយ។ កម្មវិធី Medicaid នឹងពិនិត្យមើលពាក្យស្នើសុំរបស់អ្នក និងផ្តល់ដំណឹងមកវិញថាអ្នកមានសិទ្ធិឬអត់។

### ប្រសិនបើអ្នកមានសិទ្ធិចូលរួម Medicaid អ្នកនឹងទទួលបានការរ៉ាប់រងសម្រាប់៖

- **ពិគ្រោះជាមួយវេជ្ជបណ្ឌិត**
- **ការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រដែលមិនមែនសង្គ្រោះបន្ទាន់**
- **ការស្នាក់នៅមន្ទីរពេទ្យ**
- **ការថែទាំបង្ការជំងឺ៖ ការចាក់វ៉ាក់សាំង ការថតឆ្លុះមើលសុដន់ និងការថតឆ្លុះពិនិត្យពោះវៀនធំ**
- **ការថែទាំមុនសម្រាលកូន និងពេលសម្រាលកូន**
- **ការថែទាំសុខភាពផ្លូវចិត្ត**
- **ការផ្តល់ថ្នាំពេទ្យ**
- **ការថែទាំចក្ខុ និងមាត់ធ្មេញ**

Medicaid របស់អ្នកនឹងគ្រប់គ្រងដោយអ្នកផ្តល់សេវាធានារ៉ាប់រងដែលអាចទុកចិត្តបាន ដូចជាគម្រោង Neighborhood Health Plan of Rhode Island, គម្រោង Tufts Health Public Plans, ឬគម្រោង UnitedHealthcare Community Plan។ បុគ្គលដែលមានពិការភាព និងកំពុងស្វែងរកជំនួយនៅតាមផ្ទះ ក្នុងសហគមន៍ ឬនៅកន្លែងថែរក្សាមនុស្សចាស់ជរា អាចដាក់ពាក្យសុំសេវាកម្ម និងការគាំទ្ររយៈពេលវែង (LTSS) បាន។

### តើខ្ញុំអាចដាក់ពាក្យស្នើសុំ Medicaid ដោយរបៀបណា?

គ្រប់គ្នាអាចដាក់ពាក្យតាមរយៈក្រសួងសេវាមនុស្សជាតិ (DHS) RI

- តាមអ៊ីនធឺណិត៖ ចូលគណនី ឬបង្កើតគណនីថ្មីនៅលើ **healthyrhode.ri.gov**
- តាមប្រៃសណីយ៍៖ ចូលទៅកាន់ **DHS.RI.gov/apply-now** ដើម្បីទាញយកពាក្យស្នើសុំ ហើយ ផ្ញើតាមតាមប្រៃសណីយ៍ទៅ៖<br>RI Department of Human Services<br>P.O. Box 8709<br>Cranston, RI 02920-8787
- ដោយផ្ទាល់៖ ចូលទៅកាន់ **DHS.RI.gov/apply-now** ដើម្បីទាញយកពាក្យស្នើសុំ។ ដាក់ពាក្យស្នើសុំដែលអ្នកបំពេញរួចចូលទៅក្នុងប្រអប់សុវត្ថិភាពនៅតាមការិយាល័យ DHS ណាមួយ។